# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
PHNOM PENH WATER SUPPLY AUTHORITY
លេខ:......១០៥៤ ស.ជ.ណ

ថ្ងៃ...អង្គារ...៦...រោច...ខែ.....ជេស្ឋ........ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី.....១.......ខែ...មិថុនា.....ឆ្នាំ២០២១

### សេចក្ដីជូនដំណឹង
### ស្ដីពី
### ការអញ្ជើញចូលរួមដេញថ្លៃ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់នូវទំនិញ ដូចខាងក្រោម:

១-កញ្ចប់"ក": ការផ្គត់ផ្គង់សម្លៀកបំពាក់ឯកសណ្ឋាន និងសម្ភារសន្តិសុខ សម្រាប់ឆ្នាំ២០២១
២-កញ្ចប់"ខ": ការផ្គត់ផ្គង់សម្ភារបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា និងកាមេរ៉ាសុវត្ថិភាព
៣-កញ្ចប់"គ": ការផ្គត់ផ្គង់គ្រឿងបន្លាស់ប្រព័ន្ធអគ្គិសនី

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ (រួមទាំងសេចក្ដីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១ តទៅ រៀងរាល់ម៉ោងធ្វើការ (៨ព្រឹកដល់១៦:៣០ល្ងាច) ដល់ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១ ត្រឹមវេលាម៉ោង ១៦:០០ល្ងាច ក្នុងមួយច្បាប់តម្លៃ ២០០,០០០រៀល សម្រាប់កញ្ចប់"ក,ខ" និង ៣០០,០០០រៀល សម្រាប់កញ្ចប់"គ"។

កាលបរិច្ឆេទបង្ហាញទីតាំងគ្រឿងបន្លាស់ប្រព័ន្ធអគ្គិសនីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង០៩:០០នាទីព្រឹក។ ការដែលមិនបានចូលរួមពិនិត្យនូវគ្រឿងបន្លាស់ប្រព័ន្ធអគ្គិសនីគឺជាការទទួលខុសត្រូវរបស់អ្នកចូលរួមដេញថ្លៃផ្ទាល់។

កាលបរិច្ឆេទឈប់ទទួល និងបើកសំណើដេញថ្លៃគឺ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ កញ្ចប់"ក"វេលាម៉ោង១៤:០០នាទី កញ្ចប់"ខ"វេលាម៉ោង១៤:១៥នាទី និងកញ្ចប់"គ"វេលាម៉ោង១៤:៣០នាទី នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ជាន់ទី១) តាមអាសយដ្ឋានខាងលើ។

គ្រប់ពាក្យដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការដេញថ្លៃដែលមានចំនួនដូចបានកំណត់ក្នុងឯកសារដេញថ្លៃ។

អ្នកដេញថ្លៃមានសិទ្ធិជ្រើសរើសកញ្ចប់មួយ ឬទាំងអស់។ ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ (ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

ជ. គណៈកម្មាធិការលទ្ធកម្ម
អនុប្រធានទី១

ចម្លងជូន:
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ

ហ៊ា.ណូរ៉ាវីន